ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ២០១៤ អពដ

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការរំលឹកការបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៤

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដល់ម្ចាស់អចលនទ្រព្យទាំងអស់ នៅរាជធានីភ្នំពេញ និងនៅតាមក្រុងនីមួយៗ នៃខេត្តទាំងអស់ មេត្តាជ្រាបថា ពន្ធលើអចលនទ្រព្យបានអនុវត្តប្រមូលពន្ធចាប់ពីដើមឆ្នាំ និងត្រូវបញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា ខាងមុខនេះ ដោយអនុលោមតាមកថាខណ្ឌ ៣ ចំណុច I នៃសារាចរណែនាំលេខ ០១៥ សហវ.អពដ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រហូតមកដល់ពេលនេះ អគ្គនាយកដ្ឋានពន្ធដារបានសង្កេតឃើញថា មានម្ចាស់អចលនទ្រព្យភាគតិចបានអញ្ជើញមកប្រកាសបង់ពន្ធតាមសារាចរណែនាំខាងលើនេះ ។

ដើម្បីជំរុញឱ្យការប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៤នេះ បានទាន់ពេលវេលា អគ្គនាយកដ្ឋានពន្ធដារសូមក្រើនរំលឹកដល់ម្ចាស់អចលនទ្រព្យទាំងអស់ ដែលពុំទាន់បានបំពេញកាតព្វកិច្ចបង់ពន្ធលើអចលនទ្រព្យ មេត្តារួសរាន់មកប្រកាសបង់ពន្ធឱ្យបានទាន់ពេលវេលា មុនថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ ដោយចៀសវាងនូវការប្រជ្រៀតគ្នានៅថ្ងៃជិតផុតកំណត់ នាំឱ្យខកខានពុំបានបំពេញកាតព្វកិច្ចបង់ពន្ធនេះ។

ម្ចាស់អចលនទ្រព្យដែលបានចុះបញ្ជីនៅសាខាពន្ធដារខេត្ត-ខណ្ឌ មានលេខអត្តសញ្ញាណកម្មអចលនទ្រព្យរួចហើយ អាចអញ្ជើញទៅបង់ពន្ធនេះនៅសាខាធនាគារ កាណា ឌីយ៉ា ក.អ ឬធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលស្ថិតនៅជិតលោក-អ្នក។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានពន្ធដារបានត្រៀមផ្ដល់ជូនម្ចាស់អចលនទ្រព្យនូវបណ្ណសម្គាល់ការបង់ពន្ធលើអចលនទ្រព្យ ដើម្បីសម្រួលសម្រាប់ការប្រើប្រាស់ប្រកាសបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំបន្តទៅមុខទៀត។

ចំពោះការខកខានមិនបានដាក់លិខិតប្រកាសបង់ពន្ធទាន់ពេលខាងលើ ម្ចាស់អចលនទ្រព្យត្រូវបង់ប្រាក់ពន្ធ និងប្រាក់ពិន័យ តាមច្បាប់ជាធរមាន។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់អចលនទ្រព្យទាំងអស់មានស្មារតីគោរពច្បាប់ និងអញ្ជើញមកប្រកាសបង់ពន្ធទាន់ពេលវេលាតាមកាលកំណត់ខាងលើ ជាពុំខាន ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល